ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការ

ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

លេខៈ ០២/០៤ គ.ទ.ក ស.ស.រ

# សេចក្តីសំរេច

## ស្តីពី លក្ខខណ្ឌសំរាប់ការចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា

## ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៦០៣ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងជាប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹតលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

### សំរេច

ប្រការ ១ : គ្រឹះស្ថានឧត្តមសិក្សា (សាកលវិទ្យាល័យ និង វិទ្យាស្ថាន) ដែលបានទទួលការអនុញ្ញាតអោយបង្កើតដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានពីក្រសួងអប់រំ យុវជន និងកីឡា រយៈពេលបីខែ ក្រោយពីដំណើរការបណ្តុះបណ្តាល ត្រូវសុំការអនុញ្ញាតពី **គ.ទ.ក** ដើម្បីចេញវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

ប្រការ ២ : ដើម្បីទទួលបានការអនុញ្ញាតអោយចេញវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន គ្រឹះស្ថានឧត្តមសិក្សាទាំងនោះ ត្រូវបំពេញអោយបានតាមលក្ខខណ្ឌដូចខាងក្រោម :

- ត្រូវមានផែនការយុទ្ធសាស្ត្រ ដែលបង្ហាញពីសមត្ថភាពក្នុងការស្រូបយកនិស្សិតពេញម៉ោង យ៉ាងតិច បំផុត ៥០០ (ប្រាំរយ) នាក់ ឬ ចំនួនសមមូលនៃនិស្សិតមិនពេញម៉ោងអោយចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។
- ត្រូវមានកម្មវិធីសិក្សាលំអិត រួមបញ្ចូលខ្លឹមសារ និងរចនាសម្ព័ន្ធកម្មវិធីសិក្សា និងប្លង់គោលនៃមុខវិជ្ជា នីមួយៗ។
- ត្រូវមានសាស្ត្រាចារ្យគ្រប់គ្រាន់ ប្រកបដោយសមត្ថភាព និង បទពិសោធន៍ស្របតាមកម្មវិធីសិក្សា។
- ត្រូវមានបន្ទប់សិក្សាគ្រប់គ្រាន់ បន្ទប់ពិសោធន៍ សៀវភៅនិងឯកសារសិក្សា និងសំភារៈរូបវ័ន្តចាំបាច់ផ្សេងទៀតសំរាប់បំរើអោយការសិក្សា និង ការស្រាវជ្រាវរបស់និស្សិត និងសាស្ត្រាចារ្យស្របតាមកម្មវិធីសិក្សា។
- ត្រូវមានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដើម្បីទទួលខុសត្រូវលើដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននេះ។

ប្រការ ៣ : គ្រឹះស្ថានឧត្តមសិក្សាដែលបានទទួលការអនុញ្ញាតអោយដំណើរការបណ្តុះបណ្តាល ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវបំពេញអោយបានក្នុងការស្រូបយកនិស្សិតពេញម៉ោងយ៉ាងតិចបំផុត ៥០០ (ប្រាំរយ) នាក់ ឬ ចំនួនសមមូលនៃនិស្សិតមិនពេញម៉ោង អោយចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅពេលសុំការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធ។

ប្រការ ៤ : គ្រឹះស្ថានឧត្តមសិក្សាដែលបើកថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវរៀបចំកម្មវិធីលំអិត ដោយត្រូវមានចំនួនមុខវិជ្ជាយ៉ាងតិចបំផុត ១០ (ដប់) ស្របទៅនឹងផ្នែកជំនាញ ដែលនិស្សិតជ្រើសរើសសំរាប់សិក្សានៅថ្នាក់បរិញ្ញាប័ត្រ និងត្រូវមានចំនួនក្រេឌីតសរុបយ៉ាងតិច ៣០ (សាមសិប)។ មុខវិជ្ជាទាំងដប់នោះ ត្រូវស្រង់ចេញពីផ្នែកទាំង៤ (បួន) ខាងក្រោម :

- សិល្បៈ និង មនុស្សសាស្ត្រ ត្រូវមានយ៉ាងតិច ២ (ពីរ) មុខវិជ្ជាដោយឡែកពីគ្នា
- គណិតសាស្ត្រ វិទ្យាសាស្ត្រ និង កុំព្យូទ័រវិទ្យា ត្រូវមានយ៉ាងតិច ២ (ពីរ) មុខវិជ្ជា ដោយឡែកពីគ្នា
- វិទ្យាសាស្ត្រសង្គម ត្រូវមានយ៉ាងតិច ២ (ពីរ) មុខវិជ្ជា ដោយឡែកពីគ្នា
- ភាសាបរទេស អាចមាន :
  - ពីរភាសា ឧទាហរណ៍ : ភាសាអង់គ្លេស និង ភាសាបារាំង ឬ

o មួយភាសា ឧទាហរណ៍ : ភាសាអង់គ្លេស (១) និង ភាសាអង់គ្លេស (២) ។

- មុខវិជ្ជាយ៉ាងតិច ២(ពីរ) ទៀត ដែលជាតំរូវការចាំបាច់សំរាប់ចូលសិក្សានៅថ្នាក់បរិញ្ញាប័ត្រ ។

ប្រការ ៥ : មុខវិជ្ជាដែលត្រូវបានដាក់បញ្ចូលក្នុងផ្នែកទាំង ៤ (បួន) មានដូចខាងក្រោម :

- សិល្បៈ និង មនុស្សសាស្ត្រ : អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ទស្សនវិជ្ជា វិចិត្រសិល្បៈ តូរ្យតន្ត្រី បុរាណវិទ្យា ការសិក្សាពីសាសនា ខេមរសិក្សា និងមុខវិជ្ជាដទៃទៀតដែលមានការយល់ព្រមពី **គ.ឧ.ក** ។
- គណិតសាស្ត្រ វិទ្យាសាស្ត្រ និងកុំព្យូទ័រវិទ្យា : គណិតវិទ្យា គីមីវិទ្យា ជីវវិទ្យា រូបវិទ្យា ភុគព្ភសាស្ត្រ ការសិក្សាអំពីបរិស្ថាន វិទ្យាសាស្ត្រអនុវត្ត កុំព្យូទ័រវិទ្យា និងមុខវិជ្ជាដទៃទៀត ដែលមានការយល់ព្រមពី **គ.ឧ.ក** ។
- វិទ្យាសាស្ត្រសង្គម : វិទ្យាសាស្ត្រនយោបាយ រដ្ឋបាលសាធារណៈ សង្គមវិទ្យា ចិត្តវិទ្យា សេដ្ឋកិច្ចវិទ្យា ភូមិវិទ្យា ប្រជាសាស្ត្រ និងមុខវិជ្ជាដទៃទៀតដែលមានការយល់ព្រមពី **គ.ឧ.ក** ។
- ភាសាបរទេស : ភាសាអង់គ្លេស ភាសាបារាំង និង ភាសាដទៃទៀត ។

ប្រការ ៦ : ការជ្រើសរើសនិស្សិតអោយចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវផ្អែកលើលទ្ធផលនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ និងបទដ្ឋានលំអិតផ្សេងៗរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ៧ : អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និង គ្រប់គ្រឹះស្ថានឧត្តមសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី 22 ខែ 09 ឆ្នាំ ២០០៤

**ជ.ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**អនុប្រធានអចិន្ត្រៃយ៍**

**សុខ អាន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ គ.ទ.ក